# គាថាខ្លីៗ

ខន្តិ និងសោរច្ចៈ

ខន្តិ សេចក្តីអត់ធ្មត់

សោរច្ចំ ការប្រព្រឹត្តល្អ ឬស្លូតមិនកោងកាច

អធិប្បាយ
ពាក្យថា ខន្តិ បានដល់ អធិវាសនខន្តិ ដែលលោកពោលទុកយ៉ាងនេះថា “តត្ថ កតមា ខន្តិ? យា ខន្តិ ខមនតា អធិវាសនតា អចណ្ឌិក្កំ អនសុរោបោ អត្តមនតា ចិត្តស្ស បណ្ដាធម៌ទាំងនោះ ខន្តិ តើដូចម្ដេច? គឺ ភាពអត់ធ្មត់ ការអត់សង្កត់ ភាពមិនកាច មិនព្រហើន ភាពនៃចិត្តរីករាយ” ។

ពាក្យថា សោរច្ចំ បានដល់ ភាពស្ងៀមស្ងាត់ ដែលលោកពោលទុកយ៉ាងនេះថា “តត្ថ កតមំ សោរច្ចំ? យោ កាយិកោ អវីតិក្កមោ, វាចសិកោ អវីតិក្កមោ, កាយិកវាចសិកោ អវីតិក្កមោ ។ ឥទំ វុច្ចតិ សោរច្ចំ ។ សព្ពោបិ សីលសំវរោ សោរច្ចំ បណ្ដាធម៌ទាំងនោះ សោរច្ចៈ តើដូចម្ដេច? គឺ ការមិនប្រព្រឹត្តល្មើសតាមផ្លូវកាយ ការមិនប្រព្រឹត្តល្មើសតាមផ្លូវវាចា ការមិនប្រព្រឹត្តល្មើសតាមផ្លូវកាយនិងវាចា, នេះហៅថា សោរច្ចៈ, សូម្បីការសង្រួមក្នុងសីល ( សីលសំវរៈ ) ទាំងអស់ ក៏ចាត់ចូលក្នុងសោរច្ចៈ” ។ ( សង្គីតិសុត្តវណ្ណនា )

បទថា កាយិកោ វីតិក្កមោ ( ការមិនប្រព្រឹត្តល្មើស ដោយកាយ ) បានដល់ កាយសុចរិត ៣ ។ បទថា វាចសិកោ អវីតិក្កមោ ( ការមិនប្រព្រឹត្តល្មើស ដោយវាចា ) បានដល់ វចីសុចរិត ៤ ។ បទថា កាយិកវាចសិកោ ( ដោយកាយ និងវាចា ) នេះ ទ្រង់កំណត់យកអាជីវមដ្ឋកសីល ( សីលមានអាជីវៈជាគម្រប់ ៨ ) ដែលតាំងឡើងដោយកាយ និងវាចា ។

បទថា សព្វោបិ សីលសំវរោ ( សូម្បីការសង្រួមក្នុងសីលទាំងអស់ ) នេះ ព្រះមានព្រះភាគត្រាស់ទុក ដើម្បីសម្ដែងការកាន់យកនូវសីល ដោយចិត្ត ព្រោះបុគ្គលមិនមែនប្រព្រឹត្តអនាចារដោយកាយ និងវាចាប៉ុណ្ណោះ សូម្បីដោយចិត្ត ក៏ត្រូវប្រព្រឹត្តដូចគ្នា ៕ ( អដ្ឋសាលិនី អដ្ឋកថា )

អាជ្ជវៈ និងមទ្ទវៈ

អាជ្ជវំ សេចក្តីស្លូតត្រង់

មទ្ទវំ ( លជ្ជវំ ) ចិត្តទន់ ( ភាពជាអ្នកមានសេចក្តីអៀនខ្មាស )

អធិប្បាយ

ពាក្យថា អាជ្ជវំ បានដល់ ភាពមិនស្លូតត្រង់ ៣ ប្រភេទ គឺ គោមុត្តវង្កតា ចន្ទវង្កតា និង នង្គលកោដិវង្កតា ។ អធិប្បាយថា ភិក្ខុរូបខ្លះ ក្នុងបឋមវ័យ ប្រព្រឹត្តអនេសនៈ ២១ និង អគោចរ ៦ តែក្នុងមជ្ឈិមវ័យ និងបច្ឆិមវ័យ ជាអ្នកមានសេចក្តីខ្មាសអៀន ប្រាថ្នាការសិក្សា, នេះឈ្មោះថា គោមុត្តវង្កតា ( វៀចវេរដូចទឹកនោមគោ ) ។ ភិក្ខុរូបខ្លះក្នុងបឋមវ័យ និង បច្ឆិមវ័យ បំពេញចាតុប្បារិសុទ្ធិសីល មានសេចក្តីអៀនខ្មាស រង្កៀស ប្រាថ្នាចំពោះការ សិក្សាតែ ក្នុងមជ្ឈិមវ័យ ដូចគ្នានឹងភិក្ខុក្នុងឧទាហរណ៍ទីមួយ, នេះឈ្មោះថា ចន្ទវង្កតា ( វៀច វេរដូចវង់ព្រះចន្ទ្រ ) ។ ភិក្ខុរូបខ្លះ ទាំងក្នុងបឋមវ័យ និងមជ្ឈិមវ័យ បំពេញ ចាតុប្បារិសុទ្ធិសីល មានសេចក្តីអៀនខ្មាស រង្កៀស ប្រាថ្នាចំពោះការសិក្សា តែក្នុងបច្ឆិមវ័យ ដូចគ្នានឹងភិក្ខុរូបមុន, នេះឈ្មោះថា នង្គលកោដិវង្កតា ( វៀចវេរដូចចុងនង្គ័ល ) ។ ភិក្ខុមួយរូប លះបង់ភាពមិនត្រង់ទាំង ៣ ប្រភេទនោះចោលហើយ មានសីល មានសេចក្តី អៀនខ្មាស រង្កៀស ប្រាថ្នាចំពោះការសិក្សា ក្នុងវ័យទាំង ៣ ភាពស្លូតត្រង់របស់ភិក្ខុរូបនោះ នេះឯង ឈ្មោះថា អាជ្ជវំ ។ សូម្បីក្នុងព្រះអភិធម្មក៏ពោលទុកយ៉ាងនេះថា “តត្ថ កតមោ អជ្ជវោ។ យា អជ្ជវតា អជិម្ហតា អវង្កតា អកុដិលតា, អយំ វុច្ចតិ អជ្ជវោ បណ្តាធម៌ទាំងនោះ អជ្ជវៈ ( អាជ្ជវៈ ) តើដូចម្តេច? អជ្ជវៈនោះគឺ សេចក្តីត្រង់ មិនវៀច មិនវេរ មិនកោង នេះលោក ហៅថា អជ្ជវៈ” ។

ពាក្យថា លជ្ជវំ ( មទ្ទវំ ) បានដល់ ភាពជាអ្នកមានសេចក្តីអៀនខ្មាស ដែលលោកពោលទុក យ៉ាងនេះថា “តត្ថ កតមោ លជ្ជវោ? យោ ហិរីយតិ ហិរីយិតព្វេន ហិរីយតិ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា។ អយំ វុច្ចតិ លជ្ជវោ បណ្តាធម៌ទាំងនោះ លជ្ជវៈ តើដូច ម្តេច? គឺ អៀនខ្មាសចំពោះវត្ថុដែលគួរអៀនខ្មាស ខ្មាសចំពោះការប្រព្រឹត្តអកុសលធម៌ ដ៏លាមក, នេះលោកហៅថា លជ្ជវៈ” ៕

## សូមអស់លោកអ្នកអនុមោទនា !

ចប់